**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃអង្គារ៍ ទី២០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១៣:០០នាទីនៅក្នុងរោងចក្រហ៊ុងស៊ីង ហ្គាមិន (ខេមបូឌា)ឯ.ក អាស័យដ្ឋាន ផ្លូវជាតិលេខ២ ភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទីខេត្តតាកែវ ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-លោក Xu Mei Hua (ប្រធានរោងចក្រ)

-លោក តាំង ឡុង (ប្រធានផ្នែករដ្ឋបាល)

### ខ. ភាគីតំណាងសហជីពនិងតំណាងកម្មករនិយោជិត

១-លោក ឈិត ម៉េងគ្រុយ ២-លោក គុន វឌ្ឍនៈ ៣-លោក សម្បត្តិ ស៊ុនហេង ៤-លោក ភាន ភ័ក្ត

៥-លោក ស៊ីន ចាន់ដារ៉ា ៦-លោក ឌិន ឌាន់ ៧-លោក នួន រ៉ា។

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០១ខែដោយចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្គលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោម៖

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន៣០ដុល្លាក្នុង១ខែកំឡុងពេលព្យួរការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្តើមព្យួរការងារ កម្មករនិយោជិត ចំនួន១០៩ នាក់។ ចាប់ផ្តើមពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ។

២. រោងចក្រផ្តល់ប្រាក់ឈ្នួលគោល៣០ដុល្លាក្នុង១ខែក្នុងពេលព្យួរការងារ ។

៣.ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

៤.ចំពោះប្រាក់ឈ្នួលរោងចក្រនិងបើកជូននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១៥:៥០ នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

**ក.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត**



Scanned with CamScanner

ខ.ភាគីប្រធានក្រុម

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

ថ្ងៃច័ន្ទ១៣រោច ខែចេត្រ-ពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ហ៊ុងស៊ីង ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ**

Scanned with CamScanner